ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៩៩៦.លស....../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែធ្នូ....... ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** : ការរៀបចំបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៦។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តផែនការថវិកាឆ្នាំ២០១៦ ដើម្បីបិទបញ្ជីគណនេយ្យដំណាច់ឆ្នាំ២០១៦ខាងមុខនេះ។ ដើម្បីធានាឱ្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៦នេះមានភាពត្រឹមត្រូវ និងទាន់ពេលវេលា លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើរាជធានី ខេត្ត ដែលអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទីពីរ (២០១៥-២០១៧) រៀបចំការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៦របស់ខ្លួន ដោយអនុវត្តដូចខាងក្រោម ៖

- កិច្ចប្រតិបត្តិការហិរញ្ញវត្ថុឆ្នាំ២០១៦ ត្រូវបញ្ចប់ត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦
- ជំរុញរដ្ឋបាលក្រុង ស្រុក និងមន្ទីរពាក់ព័ន្ធផ្សេងៗ ឱ្យផ្ញើសំណុំឯកសារជម្រះបុរេប្រទានមកកាន់ទីចាត់ការហិរញ្ញវត្ថុឱ្យបានត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីធ្វើការជម្រះ និងទូទាត់ ជៀសវាងការកកស្ទះនៅពេលចុងឆ្នាំ
- បញ្ចប់ការទូទាត់បេឡាសាច់ប្រាក់ និងបង្វែរសមតុល្យចូលគណនីធនាគាររបស់រាជធានី ខេត្តត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦
- ពិនិត្យបញ្ជីបុរេប្រទាន និងធ្វើការជម្រះបុរេប្រទានទាំងអស់ ព្រមទាំងការទូទាត់ផ្សេងៗឱ្យបានមុន ឬត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦
- ប្រគល់មូលប្បទានប័ត្រដែលបានអនុម័តរួចដល់អ្នកផ្គត់ផ្គង់ ឱ្យបានរួចរាល់ទាំងអស់ត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦
- ពិនិត្យ និងកែតម្រូវ កិច្ចបញ្ជីការប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ឱ្យបានត្រឹមត្រូវជាចុងក្រោយ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដំណាច់ឆ្នាំ២០១៦ រួចផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប តាមសារអេឡិចត្រូនិច (Soft Copy) ត្រឹមថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧
- បង្វែរសមតុល្យសាច់ប្រាក់ចូលទៅក្នុងគណនីធនាគាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដូចខាងក្រោម ត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧។
    - គណនីឈ្មោះ NCDD-NCDDS-IP3II
    - គណនីលេខ 0001-02-157781-1-8
    - ធនាគារ អេស៊ីលីដា ភីអិលស៊ី ភ្នំពេញ

- រាជធានី ខេត្តត្រូវផ្តល់ព័ត៌មានតាមសារអេឡិចត្រូនិកបន្ទាប់ពីបង្វែរសមតុល្យសាច់ប្រាក់រួចរាល់ចូលទៅក្នុងគណនីធនាគាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដំណាច់ឆ្នាំ២០១៦ជាផ្លូវការ ដោយមានចុះហត្ថលេខាពីឯកឧត្តមអភិបាលរាជធានី ខេត្ត រួចផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧
- ការរៀបចំបច្ចុប្បន្នភាពបញ្ជីទ្រព្យសម្បត្តិរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១៦ ត្រូវបញ្ចប់ត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ និងរៀបចំផ្ញើរបាយការណ៍ជាផ្លូវការ ដោយមានចុះហត្ថលេខាពីឯកឧត្តមអភិបាលរាជធានី ខេត្ត រួចផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានមុន ឬត្រឹមថ្ងៃទី០៦ ខែមករាឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់ចែងអនុវត្តសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

អនុប្រធានប្រតិបត្តិ

ទ៉ាន់ ចំរើន